rutnin - gimbel
lasikcentre



# ការធ្វើរោគវិនិច្ឆ័យ
# និងវិធីសាស្ត្រការព្យាបាល

WWW.RUTNINGIMBEL.COM

# មជ្ឈមណ្ឌល LASIK វ័ត្តនីន គីមបិល



មន្ទីរពេទ្យឯកទេសភ្នែកវ័ត្តនីន
ជាមជ្ឈមណ្ឌលជំនាញដែលផ្តោតលើវិស័យចក្ខុរោគមុនដំបូងបំផុត នៅប្រទេសថៃ ។
ហើយប្រកបដោយបទពិសោធន៍ និងការផ្តល់ការយកចិត្តទុកដាក់ចំពោះអ្នកជំងឺជាង ៥០ ឆ្នាំ
មន្ទីរពេទ្យវ័ត្តនីននៅតែរក្សាលំដាប់ទីមួយក្នុងការទទួលបានការជឿជាក់ទុកចិត្តពីអ្នកជំងឺ ។

ចាប់តាំងពីឆ្នាំ ១៩៩២ មក
ក្រុមគ្រូពេទ្យឯកទេសរបស់យើងបានចាប់ផ្តើមប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបឈាន
មុខគេដែលផ្តោតសំខាន់ទៅលើការវះកាត់ភ្នែកម៉្ញូបគ្រប់ប្រភេទ ។

នៅមជ្ឈមណ្ឌល LASIK វ័ត្តនីន គីមបិល ក្រុមគ្រូពេទ្យជំនាញយើងខ្ញុំអាចផ្តល់
នូវមធ្យោបាយព្យាបាលភ្នែកម៉្ញូបដោយការប្រើប្រាស់បច្ចេកវិទ្យាកាំរស្មីទំនើបចុងក្រោយ
បំផុត ដូចជា ReLEx SMILE ។

# ការត្រួតពិនិត្យមុនពេលវះកាត់ និង តំណាក់កាលក្រោយការវះកាត់







## ការត្រួតពិនិត្យមុនពេលវះកាត់

នៅអំឡុងពេលជួបពិគ្រោះលើកដំបូង ក្រុមគ្រូពេទ្យជំនាញនឹងធ្វើការត្រួតពិនិត្យយ៉ាងល្អិតល្អន់ដោយផ្តោតទៅលើ ការសិក្សាស៊ីជម្រៅទៅលើកម្រាស់ និង កំណោងកញ្ចក់ភ្នែក ការសិក្សាសរសៃបាតភ្នែកដោយការដាក់ថ្នាំពង្រីកកូនក្រមុំភ្នែក ដែលគ្មានការឈឺចាប់ ។បន្ទាប់មក ក្រុមគ្រូពេទ្យយើងខ្ញុំនឹងធ្វើការពន្យល់អំពីស្ថានភាពភ្នែករបស់លោកអ្នក ដើម្បីធ្វើការកំណត់បានថា ភ្នែករបស់លោកអ្នកអាចសាកសមគ្រប់លក្ខណៈ ក្នុងការធ្វើការបាញ់កាំរស្មីម៉្សូបភ្នែក។ ដោយប្រកាន់យកនូវ គុណភាពនៃការមើលឃើញច្បាស់របស់លោកអ្នកជាអទិភាពការបាញ់ កាំរស្មីភ្នែកម៉្សូបនឹងត្រូវបានធ្វើឡើងបន្ទាប់ពីភ្នែករបស់លោកអ្នក មានលក្ខណៈឆ្លើយតបទៅនឹងការពិនិត្យល្អិតល្អន់របស់ក្រុមគ្រូពេទ្យយើងតែប៉ុណ្ណោះ។

## លក្ខខណ្ឌតំរូវការ ក្នុងការពិនិត្យ



- ត្រូវបញ្ឈប់ការពាក់លែនកញ្ចក់ទន់ ( Soft Contact Lens ) យ៉ាងហោច ៧ ថ្ងៃមុនការពិនិត្យ និង ៣ សប្ដាហ៏ សំរាប់លែនកញ្ចក់រឹង ( Hard Contact Lens )
- សូម្របមូលយកមកនូវថ្នាំលេប ឬ បន្តកែ់ភ្នកទាំងអសៃ់ដលកំពុងេប្រើ ឬ វេជ្ជបញ្ជារបស់ថ្នាំទាំងអសៃ់ដលធ្លាបេ់ប្រើ មកេអាយគ្រូពេទ្យមើល
- ចាតែ់ចងយាន្តជំនិះត្រលប់េទាវិញបន្ទាប់ពីពិនិត្យរួច ដោយសារភែ្នកអាចមាន ការស្រវាំងមួយរយៈពេលេក្រាយពិនិត្យរួច។

## ការណាត់ជួបក្រោយការវះកាត់រួច

ក្រោយេពលវះកាត់មួយៃថ្ង រហូតដល់ មួយឆ្នាំក្រោយ លោកអ្នកនឹងេត្រូវបានតាមដានតាមការណាត់ជួបរបស់គ្រូពេទ្យេដលមានដូចខាងេក្រាម

- ការតាមដានជាចាំបាច ក្រោយវះកាត់ ថ្ងៃទី ១ និង ថ្ងៃទី ៧
- ការតាមដានបែន្ថម ក្រោយវះកាតែ់ខទី១ ខែទី៣ ខែទី ៦ និង ១ ឆ្នាំ

ក្រុមគ្រូពេទ្យេន រ័ត្តនីន គីមប៊ល មានបទពិេសាធន៍ខ្ពស់ និងការវះកាត់ ឡាស៊ែរ ។ ស្រមាប់ការពិនិត្យ ការវិនិច្ឆ័យមុនវះកាត់ និងការវះកាត់ មិនៃត

# ReLEx SMILE







ជាបច្ចេកវិទ្យាវះកាត់ចុងក្រោយ ដែលទំនើបនិងមានសុវត្ថិភាពបំផុត បច្ចេកវិទ្យាអាចអោយគ្រូពេទ្យ
ប្រើប្រាស់ពន្លឺកាំរស្មីក្នុងពេលតែមួយដើម្បី បង្កើតស្រទាប់ស្តើងមួយក្នុងកញ្ចក់ភ្នែក
កាត់កញ្ចក់ភ្នែកក្នុងទំហំតូច ( ២ ទៅ ៤ មីលីម៉ែត្រ ) បន្ទាប់មកស្រទាប់ស្តើងនោះនឹងត្រូវបានយក
ចេញតាមមុខកាត់ដែលបានបង្កើតនោះ រួចធ្វើអោយមានការប្រែប្រួលទំរង់របស់កញ្ចក់ភ្នែក និង
ជាពីភាពម្ញូបភ្នែក។ ដោយសារការវះកាត់នេះមិនត្រូវបានប៉ះពាល់ខ្លះទៅលើសិរីរាង្គ កញ្ចក់ភ្នែក
ដូចនេះភាពឈឺចាប់ ក្នុងអំឡុងពេល និង ក្រោយការវះកាត់ គឺមានតិចតួចបំផុត។
គុណសម្បត្តិដ៏ធំនៃបច្ចេកទេសនេះ គឺ ការប្រើប្រាស់ពេលវះកាត់តិច
ភាពឈឺចាប់តិចតួច និង មុខរបួសឆាប់សះ។

# Femto LASIK

បច្ចេកទេសនេះ ត្រូវបានទទួលការពេញនិយមនិង ត្រូវបានប្រើប្រាស់ក្រុមគ្រូពេទ្យទូទៅពិភពលោកដើម្បី ព្យាបាលម្ញុំបភ្នែកដោយទទួលបានលទ្ធផលគួរអោយកត់សម្គាល់។

ជាតំបូងគ្រូពេទ្យវះកាត់នឹងបង្កើតជាសន្ទះស្តើងមួយស្រទាប់នៅផ្ទៃខាងមុខនៃកញ្ចក់ភ្នែកជាមួយនឹង ពន្លឺកាំរស្មី។ បន្ទាប់មក បន្ទះនោះត្រូវបានសើយឡើង ដើម្បីប្រើប្រាស់ ពន្លឺកាំរស្មីទីពីរបាញ់ទៅលើផ្ទៃ ខាងក្នុងនៃកញ្ចក់ភ្នែក ដែលផ្តល់អោយនូវការមើលឃើញច្បាស់ក្រោយការវះកាត់។ ចុងបញ្ចប់ ស្រទាប់កញ្ចក់ខាងក្រៅនៃកញ្ចក់ភ្នែក នឹងត្រូវបិតគ្របនៅកន្លែងដើមវិញ នោះការវះកាត់បានបញ្ចប់ជាស្ថាពរ។

ខុសប្លែកពីបច្ចេកទេស LASIK ពីមុន Femto LASIK គឺជាការវះកាត់ភ្នែកម្ញុំបដែល ផ្អែកទាំងស្រុងទៅលើ ពន្លឺកាំរស្មី។ វាបានផ្តល់ការវះកាត់ដែលមានភាពរលូន មានផលពិបាកក្រោយការវះកាត់តិចតួចជាងមុន ជាពិសេសគឺការឆាប់មើលឃើញច្បាស់ក្រោយពេលវះកាត់។







# វិធីសាស្ត្រផ្សេងៗ





## LASIK
## ( Laser-assisted in situ Keratomileusis )

ជាបច្ចេកវិទ្យាជំនាន់ថ្មីនៃការវះកាត់កែកំហើញដោយកាំរស្មីដោយផ្តោតទៅលើការគ្របឡើងវិញនៃស្រទាប់របស់កញ្ចក់ភ្នែក។ ស្រទាប់គបឡើងវិញនេះ ត្រូវបានបង្កើតឡើងដោយឧបករណ៍ពិសេសដែលចក្ខុបណ្ឌិត បកស្រទាប់ខាងលើចេញ រួចហើយធ្វើការចិត្រស្រទាប់ខាងក្នុងរបស់កញ្ចក់ភ្នែកដោយកាំរស្មី excimer laser។ ចុងបញ្ចប់ ស្រទាប់ខាងលើនេះ ក៏ត្រូវបានយកមកគបនៅកន្លែងដើមវិញ ដែលជំរុញឱ្យមុខរបួសមានការជាសះលឿនជាងមុន។

---

## PRK ( Photorefractive Keratectomy )

ជាបច្ចេកវិទ្យាវះកាត់ស្រទាប់កញ្ចក់ភ្នែកដំបូងបង្អស់ ហើយត្រូវបានគេយកមកប្រើចំពោះការកែជំងឺភ្នែកម៉្យូប រឺ អាក់ស្ទីម៉ាត កំរិតទាប។ ដំបូង, ចក្ខុបណ្ឌិតនឹង ចិតយកស្រទាប់ស្តើងផ្នែកខាងលើកញ្ចក់ភ្នែកចេញ, បន្ទាប់មក គាត់ធ្វើការចិត្រស្រទាប់ខាងក្នុងរបស់កញ្ចក់ភ្នែកដោយ excimer laser ដើម្បីកែភ្នែកម៉្យូប។ ស្រទាប់ខាងលើដែលចិតចេញនេះ នឹងចាប់ផ្តើមដុះឡើងវិញក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ។





# បេក្ខភាពអ្នកជំងឺដែលអាចធ្វើការវះកាត់បាន

ក្រុមគ្រូពេទ្យភ្នែកតែងអនុវត្តិទៅតាមក្រមសីលធម៌នៃមន្ទីរពេទ្យរត្តនីន ដែលបង្កើតដោយ វេជ្ជបណ្ឌិត ឧទ័យ រ័ត្តនីន ។ ចំពោះបេក្ខភាពដែលអាចទទួលការព្យាបាលវះកាត់នេះបាន លុះត្រាតែសមស្របទៅតាមលក្ខខណ្ឌបច្ចេកទេសដែលបានកំណត់ទុកជាមុន។

លក្ខខណ្ឌបច្ចេកទេសទាំងនេះ ត្រូវបានពិនិត្យដោយក្រុមអ្នកជំនាញរបស់យើង។ ចំពោះបេក្ខជនដែលទទួលការព្យាបាលវះកាត់ ចាំបាច់ត្រូវមានសុខភាពទូទៅល្អ និង ត្រូវមានគំហើញដែលមិនមានការប្រែប្រួល។

ក្រៅអំពីបញ្ហាផ្នែកវេជ្ជសាស្ត្រ ចក្ខុបណ្ឌិតរបស់យើងក៏ ផ្តោតការយកចិត្តទុកដាក់ ទៅលើពេលវេលា ក្នុងការពិភាក្សាជាមួយរាល់អ្នកជំងឺដែលចូលមកពិគ្រោះ ដូចជា ការផ្តល់កំលាំងចិត្ត, ការរំពឹងទុកក្រោយការវះកាត់ និងការយល់ឱ្យច្បាស់ អំពីបច្ចេកទេសនៃការវះកាត់។

ក្រោយពីបានពិនិត្យ និង ពិភាក្សាយ៉ាងយកចិត្តទុកដាក់ អ្នកជំងឺដែលសមស្របសំរាប់ការវះកាត់ នឹងត្រូវបានជ្រើសរើសជាបេក្ខជនសំរាប់ទទួលការវះកាត់កែគំហើញដោយកាំរស្មី ។



## លក្ខខណ្ឌមូលដ្ឋាន

- អាយុ ៖ មិនតិចជាង ២០ ឆ្នាំ
- មានសុខភាពល្អ
- ស្ថានភាពភ្នែកល្អ ( មិនមានជំងឺភ្នែក, មិនមានភ្នែកស្ងួត )
- មិនមានផ្ទៃពោះ, មិនមានការបំបៅដោះកូន ។

# ទំនាក់ទំនង

ក្រុមអ្នកជំនាញរបស់យើង នឹងអាចផ្តល់ព័តមានសំខាន់ៗ និងអាចកំណត់ថ្ងៃណាត់ជួប សំរាប់ ពិគ្រោះជាមួយចក្ខុបណ្ឌិតរបស់យើង ក៏ដូចជាការពិនិត្យភ្នែកមុនពេលវះកាត់ផងដែរ ។ ប្រសិនបើត្រូវណាត់គ្រូពេទ្យជំនាញណាមួយដែលលោកអ្នកស្គាល់សូមមេត្តាបញ្ជាក់ឈ្មោះគ្រូពេទ្យឱ្យបានច្បាស់ផងពេលធ្វើការណាត់ ។

**ម៉ោងធ្វើការដូចខាងក្រោមគឺ ៖**

| | |
|---|---|
| ថ្ងៃច័ន្ទ - សៅរ៍ | 08.00 - 18.00 |
| ថ្ងៃអាទិត្យ | 08.00 - 17.30 |
| ថ្ងៃឈប់សម្រាក | 08.00 - 16.00 |

rutnin - gimbel
lasikcentre

មជ្ឈមណ្ឌល LASIK រ័ត្តនីន គីមប៊ិល
អគារ Q House Asoke 66 ជាន់ទី 16 វិថីសុខុមវិត ផ្លូវលេខ 21 (អ:ស៊ោក) ,
ខ្លងទើយនឿ, ខណ្ឌវឌ្ឍណា,ទីក្រុង បាងកក 10110, ប្រទេសថៃ
+66 ( 0 )2 056 3355 / +66 ( 0 )6 1415 3555
info@rutningimbel.com www.rutningimbel.com